**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ...០៩៩...សបស/ប្រកស

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១

# ប្រកាស

## ស្តីពី

## ការផ្តល់ស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អ សំរាប់ភោជនីយដ្ឋាន អាហារដ្ឋាន

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញសារាចររាជរដ្ឋាភិបាលលេខ០៣ស.រចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៥ស្តីពីការគ្រប់គ្រងគុណភាព និងវិធានការត្រួតពិនិត្យគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងចំណីអាហារ ដែលមានប្រើសារជាតិគីមី
- បានឃើញប្រកាសអន្តរក្រសួងលេខ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ និងសម្របសម្រួលស្ថាប័នកិច្ចនៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារចាប់ពីកសិដ្ឋាន ដល់តុបរិភោគ
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល ។

## <u>សម្រេច</u>

**ប្រការ១ :** ដើម្បីធានានូវអនាម័យ សុវត្ថិភាពចំណីអាហារតាមភោជនីយដ្ឋាន អាហារដ្ឋានដែលកំពុងធ្វើអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសុខាភិបាលតំរូវអោយភោជនីយដ្ឋាន អាហារដ្ឋាន ទាំងអស់មានស្លាកសញ្ញាសំគាល់ "គោលការណ៍អនុវត្តអនាម័យល្អ" ។



ទីស្តីការរដ្ឋមន្ត្រីក្រសួងសុខាភិបាល ,លេខ ១៥១-១៥៣ វុក្ខវិថី កម្ពុជាក្រោម ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៤២៦ ០៣៥/៤២៦ ៨៤១ ទូរស័ព្ទ: (៨៥៥-២៣) ៧២២ ៩៣៣

**ប្រការ២ :** ស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អត្រូវកំណត់ទៅតាមកម្រិតដែលតាងដោយអក្សរ អង់គ្លេស អេ(A) ប៊ី(B) ស៊ី(C) :

- អក្សរ **A** : ផ្តល់ជូនភោជនីយដ្ឋាន អាហារដ្ឋានដែលអនុវត្តបានល្អប្រសើរ
- អក្សរ **B** : ផ្តល់ជូនភោជនីយដ្ឋាន អាហារដ្ឋានដែលអនុវត្តបានល្អ
- អក្សរ **C** : ផ្តល់ជូនភោជនីយដ្ឋាន អាហារដ្ឋានដែលអនុវត្តបានល្អបង្គួរ ។

**ប្រការ៣ :** ស្លាកសញ្ញាគោលការណ៍អនុវត្តអនាម័យល្អសំរាប់ភោជនីយដ្ឋាន អាហារដ្ឋាន មានលក្ខណៈដូចខាងក្រោមៈ

ក. ជាបន្ទះប្លាស្ទិកមានទទឹង៦០សម និងបណ្តោយ ៨០សម ព័ទ្ធជុំវិញដោយ ខ្សែបរិមាត្រពណ៌លឿង :

១. ផ្នែកខាងលើមានផ្ទៃពណ៌ខៀវ(ទឹកប៊ិច) មានទំហំ ៥៥ សម គុណ ៥៧,៥ សម មានសរសេរអក្សរ "គោលការណ៍អនុវត្តអនាម័យល្អ " និងអក្សរអង់គ្លេស "**GOOD HYGIENE PRACTICE**"

២. មានអក្សរស្ថិតក្នុងរង្វង់បញ្ជាក់ពីចំណាត់ថ្នាក់នៃការអនុវត្តអនាម័យ អមដោយស្លាបព្រាមួយ និងសមមួយ ។

ខ. ផ្នែកខាងក្រោមមានផ្ទៃពណ៌លឿង ទំហំ ៦០ សម គុណ ២០ សម និងសរសេរអក្សរ :

១. និមិត្តសញ្ញាក្រសួងសុខាភិបាល នៅផ្នែកខាងឆ្វេង

២. នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងអក្សរអង់គ្លេស **Department of Drug and Food** ស្ថិតនៅចំកណ្តាល

៣. លេខអនុញ្ញាត កាលបរិច្ឆេទ និងថ្ងៃខែផុតកំណត់របស់ស្លាកសញ្ញា ស្ថិតនៅផ្នែកខាងឆ្វេង ។

**ប្រការ៤ :** អាជីវករគ្រប់រូបដែលប្រកបអាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវតែមកបំពេញបែបបទសុំស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អ នៅតាមមន្ទីរសុខាភិបាលរាជធានី ខេត្ត ។

**ប្រការ៥ :** ស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អ មានសុពលភាព ២ ឆ្នាំ អាជីវករត្រូវដាក់ពាក្យសុំបន្តសុពលភាពនៅមន្ទីរសុខាភិបាលរាជធានី ខេត្ត ឱ្យបាន ២ ខែមុនផុតកំណត់ ។

**ប្រការ៦ :** មន្ទីរសុខាភិបាលរាជធានី ខេត្តអាចផ្តល់ស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អជូនម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋានបាន លុះត្រាតែមានការឯកភាពពីមន្ត្រីត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងរបស់ក្រសួងសុខាភិបាល ។

**ប្រការ៧:** មន្ត្រីត្រួតពិនិត្យសុវត្ថិភាពចំណីអាហារនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាងរបស់ក្រសួងសុខាភិបាលមានភារកិច្ចចុះតាមដាន និងវាយតំលៃលក្ខខណ្ឌអនាម័យសុវត្ថិភាពចំណីអាហារនៅគ្រប់ភោជនីយដ្ឋាន អាហារដ្ឋានដែលបានទទួលស្លាកសញ្ញាសំគាល់គោលការណ៍អនុវត្តអនាម័យល្អ ។

**ប្រការ៨ :** ក្រសួងសុខាភិបាលមានសិទ្ធិដកហូតស្លាកសញ្ញាសំគាល់គោលការណ៏អនុវត្តអនាម័យល្អ ដោយគ្មានលក្ខខណ្ឌ ក្នុងករណីភោជនីយដ្ឋាន អាហារដ្ឋានដែលបានទទួលស្លាកសញ្ញាសំគាល់រួច ហើយមិនអនុវត្តតាមលក្ខខណ្ឌកំណត់របស់ក្រសួងសុខាភិបាល ឬបង្កផលប៉ះពាល់ដល់សុខភាពអ្នកបរិភោគ ។

**ប្រការ៩ :** ជនទាំងឡាយណាក្លែងបន្លំស្លាកសញ្ញាសំគាល់គោលការណ៏អនុវត្តអនាម័យល្អ ដូចមានចែងក្នុងប្រការ២ និង៣ ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន ។

**ប្រការ១០ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយទៅនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១ :** ខុទ្ទកាល័យរបស់ក្រសួងសុខាភិបាល អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល អគ្គាធិការដ្ឋានក្រសួងសុខាភិបាល នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង និងមន្ទីរសុខាភិបាលរាជធានី ខេត្ត មានភារកិច្ចអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**<u>ចំលងជូន:</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងពាក់ព័ន្ធ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- សាលារាជធានី-ខេត្ត
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
- នាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង
- គ្រប់មន្ទីរសុខាភិបាលរាជធានី-ខេត្ត
- សមាគមភោជនីយដ្ឋាន
- ឯកសារ និងកាលប្បវត្ត

ម៉ម_ប៊ុនហេង